00358842

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 06 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/27

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 08 / 2009
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អសប

២៨ ខែ ឧសភា ឆ្នាំ ២០០៩ -ថ្ងៃទី២៣

រៀបចំដោយ: សែ កុលវុឌ្ឍី និង Natacha Wexels-Riser

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន) ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក Crippa MATTEO,លោក លឹម ស៊ុយហុង,លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Alexander Bates, លោក ប៉ាក ចន្ទលីណូ,លោក ពេជ្រ សម្បត្តិ,លោក ជា ផល្លា |
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃនីតិវិធី ២៨ ឧសភា ២០០៩ /សាធារណៈ:

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

| |
|---|
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux, លោកស្រី Marie-Paule Canizares, លោកស្រី Heleyn Unac, លោក ចាន់ រ៉ាវុធ, កញ្ញា Lucile Nattiez |
| មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ហុងគឹមសួន,លោក គង់ ពិសី,លោក យុង ផានិត,កញ្ញា Silke Studzinsky, លោក គីម ម៉េងឃី,កញ្ញា ទី ស្រីនណា, លោក Alain Werner, លោកស្រី Elizabeth Resandratana |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោកស្រី Maryvonne Maniacky, លោក Scott Bywater, លោក Pierre Cozette, លោកស្រី Julie Massé. |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ ១៦.៤៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៥០ | បញ្ចប់ម៉ោង៖ ១១.៣០ |
| សម្រាក | ចាប់ផ្តើមម៉ោង៖ ១២.១៥ | បញ្ចប់ម៉ោង៖ ១៣.៥០ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖១៤.៥៥ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការសួរសំណួរដល់អ្នកជំនាញ Craig Etcheson ទាក់ទងនិងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីសកម្ពុជា | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ | ៩.១១ | ១១.៣៦ |
| ការបញ្ជាក់របស់អង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ៩.៤២ | |
| ការសួរសំណួរដល់អ្នកជំនាញ Craig Etcheson ទាក់ទងនិងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីសកម្ពុជា | មេធាវីការពារជនជាប់ចោទ | ១១.៣៧ | ១៦.៤១ |

| | | | |
|---|---|---|---|
| សេចក្ដីសម្រេចក្នុងការកែប្រែកាលបរិច្ឆេទក្នុងការផ្ដល់យោបល់ទៅលើសំណុំរឿងតុលាការយោធា | អង្គជំនុំជម្រះ | ១៥.២០ | ១៥.២១ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការសួរសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនិងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីសកម្ពុជានៅមន្ទីរស២១ដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

- មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១បានតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនិងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីសកម្ពុជានៅមន្ទីរស ២១។

**ការសួរសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនិងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីសកម្ពុជានៅមន្ទីរស២១ដោយមេធាវីការពារក្ដី**

- មេធាវីការពារជនជាប់ចោទតាំងសំណួរទៅអ្នកជំនាញ ទាក់ទងនិងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីសកម្ពុជានៅមន្ទីរ ស ២១។
- មេធាវីការពារក្ដីអន្តរជាតិបានជូនដំណឹងថាគាត់នឹងអវត្តមានចាប់ពីថ្ងៃទី០៨ រហូតដល់ថ្ងៃទី១០ ខែមិថុនា នៅក្នុងអំឡុងពេលដែលគាត់អវត្តមាន ត្រូវជំនួសដោយលោកស្រី Marie Paule Canizares គាត់នឹងត្រឡប់មកវិញនៅថ្ងៃទី ១១ ខែមិថុនា ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោងរបស់ អជសដ | លេខយោងរបស់ កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| E3/26 | D20 | កំណត់ហេតុសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ថ្ងៃទី០២ តុលា ឆ្នាំ២០០៧ | សម្ងាត់ | មាននៅក្នុងប្រអប់ E3 |
| E3/32 | D2-15 | កំណត់ហេតុនៃការវិភាគដោយ | សាធារណៈ | 00146822-00146887 |

| | | | | |
|---|---|---|---|---|
| | | អ្នកស៊ើបអង្កេតរបស់ការិយាល័យសហព្រះរាជអាជ្ញា Craig C. Etcheson | | មាននៅក្នុងប្រអប់ E3 |
| E3/17 | D30 | កំណត់ហេតុស្តាប់ចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ២៩ ខែវិច្ឆិកា ២០០៧ | សម្ងាត់ | មាននៅក្នុងប្រអប់ E3 |
| E3/11 | D38 | កំណត់ហេតុស្តាប់ចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ២១ ខែមករា ២០០៨ | សម្ងាត់ | មាននៅក្នុងប្រអប់ E3 |
| E3/218 | D52 | កំណត់ហេតុនៃការតទល់មុខគ្នា | សម្ងាត់ ធ្វើចំណាត់ថ្នាក់ឡើងវិញពេលក្រោយ | 00165434-00165441 |
| E3/219 | D16 | កំណត់ហេតុស្តាប់ចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៥ ខែកញ្ញា ២០០៧ | សម្ងាត់ | 00147579-00147585 |
| E3/13 | IS 6.3 | សេចក្តីសម្រេចរបស់គណៈមជ្ឈិមទៅលើបញ្ហាផ្សេងៗ ចុះថ្ងៃទី ៣០ ខែមីនា ១៩៧៦ | សាធារណៈ | 00003141 មាននៅក្នុងប្រអប់ E3 |
| E3/28 | IS 9.1 | លក្ខតិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ១៩៧៦ | សាធារណៈ | មាននៅក្នុងប្រអប់ E3 |
| E3/30<br>E3/14 | IS 13.45<br>IS 13.2 | កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី០៩ តុលា ១៩៧៥ | សាធារណៈ | 00292868-00292886, 00019108-00019126 មាននៅក្នុងប្រអប់ E3 |

| | | | | |
|---|---|---|---|---|
| | | | | មិនតម្រូវឱ្យជូនដំណឹងទេ |
| E3/220 | D92/1 ឧបសម្ព័ន្ធ៥ | បញ្ជីឈ្មោះអ្នកទោសកម្ពុជាប្រជាធិបតេយ្យ (មជ្ឈមណ្ឌលឯកសារកម្ពុជា) | សាធារណៈ | 00194821-00194829 |
| E3/221 | IS 19.101 | កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ | សម្ងាត់ | 00087303-00087332, 00292776-00292802, 00233382-00233428 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

1. អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់ថា មាត្រា១៥ នៃអនុសញ្ញាស្តីពីការហាមឃាត់ការធ្វើទារុណកម្មបានចែងថា “ភាគីរដ្ឋត្រូវធានាថា ឯកសាររបាយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាង ជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ ដែលបានធ្វើឡើងដោយសារការធ្វើទារុណកម្ម លើកលែងតែឯកសាររបាយការណ៍នោះត្រូវបានធ្វើឡើងសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទ នៃអំពីទារុណកម្ម” ។ អង្គជំនុំជម្រះចង់ធ្វើការបំភ្លឺឱ្យបានច្បាស់ទៅលើអ្វីដែលយើងបានចង្អុលបង្ហាញកាលពីប៉ុន្មានថ្ងៃមុន ។ អង្គជំនុំជម្រះចង់បញ្ជាក់អំពីសារៈសំខាន់នៃអង្គហេតុដែលថាសវនាការនេះគឺត្រូវគោរពមាត្រា១៥នៃអនុសញ្ញាស្តីពីការធ្វើទារុណកម្ម។ បទប្បញ្ញត្តិនេះគឺបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ហើយក៏បានឆ្លុះបញ្ចាំងនៃវិធាន២១(៣)នៃវិធានផ្ទៃក្នុង ដែលបានចែងថា “មិនមានទម្រង់នៃការបង្ខិតបង្ខំលើរូបរាងកាយ ឬក៏ការគំរាមកំហែងណាមួយ មិនថាធ្វើឡើងដោយផ្ទាល់ចំពោះអ្នកត្រូវបានគេសម្ភាស ឬក៏អ្នកដែលផ្សេងៗទៀត មិនត្រូវបានយកមកប្រើប្រាស់ឡើយ ។ ហើយបើសិនជាការបង្ខំ ឬក៏ការគំរាមកំហែងនោះត្រូវបានប្រើប្រាស់ ចម្លើយដែលបានកត់ត្រានោះ គឺមិនអាចទទួលយកបានជាភស្តុតាងនៅចំពោះអង្គសវនាការនោះទេ” ។ ក្នុងការអនុវត្តចំណុចនេះ មានន័យថាចម្លើយសារភាពដែលបានធ្វើ

ឡើង ហើយបានធ្វើឡើងក្រោមការធ្វើទារុណកម្មនោះ គឺជាអង្គហេតុដែលទទួលយកបាន ។ ប៉ុន្តែខ្លឹមសារនៃការសារភាព ដែលធ្វើឡើងដោយទារុណកម្មនោះ គឺមិនអាចយកមកធ្វើការទទួលយកបានថាវាជាចម្លើយមួយដែលពិតប្រាកដនោះទេ ។ ប្រសិនបើភាគីណាមួយចង់លើកឡើងអំពីភាពពិតប្រាកដ ឬក៏ខ្លឹមសារនៃចម្លើយសារភាពទាំងអស់នោះ វាជាការចាំបាច់ក្នុងការបង្ហាញជាមុនឱ្យឃើញថា ប្រសិនបើចម្លើយសារភាពត្រូវបានធ្វើឡើង ដោយមានទារុណកម្ម ឬក៏ដោយមានការគំរាមកំហែង នៃអំពើទារុណកម្ម ដោយសារមូលហេតុនេះ ភាគីគួរតែពិចារណា ថាតើការពិនិត្យទៅលើខ្លឹមសារនៃចម្លើយសារភាពទាំងអស់នោះ គឺវាគ្រប់គ្រាន់ហើយមានសារសំខាន់ពេញលេញក្នុងការសួរទៅលើលក្ខខណ្ឌ ឬក៏ស្ថានភាពមួយចំនួន ដែលចម្លើយសារភាពនោះត្រូវបានធ្វើឡើង។

2. សេចក្តីសម្រេចកែប្រែកាលបរិច្ឆេទចំពោះការផ្តល់យោបល់លើសំណុំរឿង ដែលទទួលបានពីតុលាការយោធា ។ ដោយសារតែមានមូលហេតុមួយចំនួន សំណុំរឿងរបស់តុលាការយោធាទាំងមូលមិនទាន់បានបកប្រែចប់នៅឡើយទេ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ផ្នែកដែលមិនទាន់បានបកប្រែចប់នោះ គឺមិនមានសារៈសំខាន់ចំពោះអង្គជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំនោះទេ ។ អង្គជំនុំជម្រះសាលាដំបូងដឹងថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើសុំដោះលែងជនជាប់ចោទ គឺត្រូវប្រកាសនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ ។ អង្គជំនុំជម្រះទទួលស្គាល់ថា ការលំបាកនៃការបកប្រែ ធ្វើឱ្យភាគីមានរយៈពេលតិចក្នុងការផ្តល់យោបល់របស់ខ្លួន លើសំណុំរឿងរបស់តុលាការយោធានេះ ។ ប៉ុន្តែដើម្បីឱ្យអង្គជំនុំជម្រះអាចចេញសេចក្តីសម្រេចរបស់ខ្លួនបាននៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងសូមស្នើដល់ភាគីទាំងអស់ឱ្យផ្តល់យោបល់លើសំណុំរឿងនេះ យ៉ាងយូរបំផុតត្រឹមម៉ោងបួនរសៀលថ្ងៃច័ន្ទ ទីមួយ ខែមិថុនា ឆ្នាំ២០០៩ ។

3. ដីកាបង្គាប់ឱ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩ ។

<u>ដីកាសម្រាប់ការលើកវារកាលសវនាការ</u>

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃនីតិវិធី ២៨ ឧសភា ២០០៩ /សាធារណៈ

| |
|---|
| ការពន្យារសវនាការ៖ សវនាការនឹងបន្តបន្ទាប់ពីការឈប់សម្រាកមិនធ្វើសវនាការ នៅថ្ងៃច័ន្ទ ទី ០៨ ខែ មិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ ព្រឹក ។<br>សវនាការដំណើរការយឺតយ៉ាវ បន្ទាប់ពីការសម្រាកពេលព្រឹក ដោយសារតែបញ្ហាបច្ចេកទេសនៅបន្ទប់ផ្សាយបន្តផ្ទាល់។ |

ភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩

ក្រឡាបញ្ជី

សែ កុលវុឌ្ឍី Natacha Wexels-Riser